**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គស្នងការដ្ឋាននគរបាលជាតិ**
លេខៈ ៧៣៥ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ

## អគ្គស្នងការនគរបាលជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥៨ អនក្រ.តត ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២ ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណូមពរចាំបាច់នៃការងារគ្រប់គ្រងដឹកនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ

## សម្រេច

**ប្រការ ១ ៖** ត្រូវបានប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំអគ្គស្នងការរង នៃស្នងការដ្ឋាននគរបាលជាតិ ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- នាយឧត្តមសេនីយ៍ | **នៃ ស៊ីណារិទ្ធ** | អគ្គស្នងការរង ជំនួយការដឹកនាំការងារសន្តិសុខផ្ទៃក្នុង ស៊ើបការណ៍ខាងក្រៅ និងបច្ចេកទេស និងប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម |
| ២- នាយឧត្តមសេនីយ៍ | **ខេង សុមេធ** | អគ្គស្នងការរង ជំនួយការដឹកនាំការងារព្រំដែនទទួលទិសភូមិភាគទី៤ និងភូមិភាគ៥ |
| ៣- នាយឧត្តមសេនីយ៍ | **ម៉ក់ ជីតូ** | អគ្គស្នងការរង ជំនួយការដឹកនាំការងារប្រឆាំងគ្រឿងញៀន |
| ៤- នាយឧត្តមសេនីយ៍ | **ហ៊ឹម យ៉ាន** | អគ្គស្នងការរង ជំនួយការដឹកនាំការងារនគរបាលចរាចរណ៍ សណ្តាប់ធ្នាប់សាធារណៈ និងនគរបាលទេសចរណ៍ |
| ៥- នាយឧត្តមសេនីយ៍ | **ម៉ែន វិបុល** | អគ្គស្នងការរង និងជាប្រធាននាយកដ្ឋានបុគ្គលិក |
| ៦- ឧត្តមសេនីយ៍ឯក | **ស ថេត** | អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ |
| ៧- ឧត្តមសេនីយ៍ឯក | **ឌី វិជ្ជា** | អគ្គស្នងការរង ជំនួយការដឹកនាំការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម បច្ចេកទេសសន្តិសុខ និងនាយកដ្ឋានកណ្តាលសន្តិសុខ ចារកម្ម ក្រុមស៊ើបអង្កេតបទល្មើសឆ្លងដែន Hotline ជាមួយជនបរទេស |
| ៨- ឧត្តមសេនីយ៍ឯក | **ឆាយ គឹមខឿន** | អគ្គស្នងការរង ជំនួយការដឹកនាំការងារសេនាធិការដ្ឋាន ។ |

៩- ឧត្តមសេនីយ៍ឯក **មួង សុធា** អគ្គស្នងការរង ជំនួយការដឹកនាំការងារនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

១០- ឧត្តមសេនីយ៍ឯក **អ៊ី សុខឃី** អគ្គស្នងការរង ជំនួយការដឹកនាំការងារប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន និងគ្រប់គ្រងសន្តិសុខឯកជន

១១- ឧត្តមសេនីយ៍ឯក **ឡោ សុឡេខ** អគ្គស្នងការរង និងជាស្នងការហិរញ្ញកិច្ច និងភស្តុភារ ជំនួយការដឹកនាំការងារគ្រប់គ្រងអាវុធជាតិផ្ទុះ នគរបាលបង្ការពន្លត់អគ្គីភ័យ និងសង្គ្រោះ នគរបាលការពារបេតិកភណ្ឌ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

១២- ឧត្តមសេនីយ៍ឯក **ឃឹម លាង** អគ្គស្នងការរង ជំនួយការដឹកនាំការរៀបចំផែនការការពារ និងនាយកដ្ឋានអង្គរក្ស

១៣- ឧត្តមសេនីយ៍ឯក **ជីម ផល្លី** អគ្គស្នងការរង ជំនួយការដឹកនាំការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

១៤- ឧត្តមសេនីយ៍ឯក **ជា ពៅ** អគ្គស្នងការរង ជំនួយការដឹកនាំការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា

១៥- ឧត្តមសេនីយ៍ទោ **លន់ សុផាត** អគ្គស្នងការរង ជំនួយការដឹកនាំការងារអន្តរាគមន៍ តម្រួតបទបញ្ជា និងនគរបាលការពារ

១៦- ឧត្តមសេនីយ៍ទោ **អ៊ឹង យន** អគ្គស្នងការរង ជំនួយការដឹកនាំការងារនាយកដ្ឋានកណ្តាលនគរបាលព្រំដែន ទទួលទិសភូមិភាគ១ ភូមិភាគ២ និងភូមិភាគ៣

១៧- ឧត្តមសេនីយ៍ទោ **រស់ ច័ន្ទសោភា** អគ្គស្នងការរង ជំនួយការដឹកនាំការងារយេនឌ័រ ។

**ប្រការ ២ ៖** ឯកឧត្តម លោកជំទាវ អគ្គស្នងការរងនគរបាលជាតិ មានភារកិច្ចអនុវត្តការងារផ្សេងទៀតតាមការប្រគល់ឲ្យពីអគ្គស្នងការនគរបាលជាតិ ។

**ប្រការ ៣ ៖** រាល់បទកំណត់ទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖** ប្រធានសេនាធិការ ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ ស្នងការនគរបាលរាជធានី-ខេត្ត និងដូចក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ១០ កើត ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០២២

**អគ្គស្នងការ**

ឧត្តមសេនីយ៍ សន្តិបណ្ឌិត.នេត-សាវឿន

*កន្លែងទទួល*
- *ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
- *ដូចប្រការ ៤*
- *ឯកសារ-កាលប្បវត្តិ*